# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០២៣/១៧ ក.ប/ស.រ.ឧ.ម.ហ

**សារាចរ**

**ស្តីពី**

**បទដ្ឋានអប្បបរមាសម្រាប់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រង កម្មសិក្សាការីខ្មែរទៅធ្វើការនៅប្រទេសជប៉ុន**

អនុលោមតាមអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ លើកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេសឱ្យទៅធ្វើការនៅប្រទេសជប៉ុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាការីខ្មែរទៅធ្វើការនៅប្រទេសជប៉ុន ត្រូវគោរព និងអនុវត្តទៅតាមបទដ្ឋានអប្បបរមាសម្រាប់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាការីខ្មែរទៅធ្វើការនៅប្រទេសជប៉ុន ដូចខាងក្រោម៖

១- ត្រូវជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូន សម្រាប់តែជនណាដែល

- មានបំណងច្បាស់លាស់ក្នុងការចូលរួមកម្មវិធីការងារនៅប្រទេសជប៉ុន
- មានការយល់ដឹងច្បាស់លាស់ អំពីជំនាញបច្ចេកទេស ដែលបានបណ្តុះបណ្តាល
- មានបំណងចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ បន្ទាប់ពីបានត្រឡប់មកមាតុប្រទេសវិញ ដោយប្រើប្រាស់នូវជំនាញបច្ចេកទេសដែលទទួលបានពីការបណ្តុះបណ្តាលនៅប្រទេសជប៉ុន។

២- ត្រូវកំណត់ឱ្យបានច្បាស់លាស់ អំពីមុខចំណាយនៃកម្រៃសេវា និងការចំណាយផ្សេងទៀត ដែល " កម្មសិក្សាការី និងបេក្ខជន " ត្រូវបង់ ព្រមទាំងធ្វើការផ្សព្វផ្សាយ និងពន្យល់ឱ្យបានច្បាស់លាស់អំពីមុខចំណាយទាំងនោះ ដល់កម្មសិក្សាការី និងបេក្ខជន។

៣- ត្រូវផ្តល់សេវាគាំទ្រចាំបាច់ដល់កម្មសិក្សាការី និងបេក្ខជនជំនាញបច្ចេកទេសដែលបានវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនៅប្រទេសជប៉ុនរួចមក ដូចជាត្រូវស្វែងរកការងារឱ្យពួកគាត់ធ្វើ ដើម្បីបានប្រើប្រាស់ជំនាញបច្ចេកទេសនោះឱ្យបានសមស្រប។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

៤- ត្រូវអនុវត្តតាមការកំណត់របស់ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព នៃប្រទេសជប៉ុន ឬអង្គការបណ្តុះបណ្តាលជំនាញបច្ចេកទេស សំដៅធ្វើឱ្យកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការី និងការផ្តល់ការគាំពារដល់កម្មសិក្សាការីប្រព្រឹត្តទៅដោយសមស្រប។ ការកំណត់ទាំងនោះរួមមាន ការសហការក្នុងការធ្វើអង្កេតតាមដាន ចំពោះកម្មសិក្សាការីជំនាញបច្ចេកទេស ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនៅប្រទេសជប៉ុន។

៥- ទីភ្នាក់ងារជ្រើសរើសឯកជន និងសមាជិកក្រុមប្រឹក្សាភិបាលរបស់ទីភ្នាក់ងារជ្រើសរើសឯកជន មិនត្រូវធ្លាប់បានជាប់ពន្ធនាគារ ឬត្រូវបានដាក់ពិន័យធ្ងន់ធ្ងរនៅក្នុងប្រទេសជប៉ុន ឬនៅក្នុងប្រទេសកម្ពុជានៅក្នុង រយៈពេលប្រាំឆ្នាំចុងក្រោយ។

៦- គ្រប់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ត្រូវធ្វើសកម្មភាពទាំងឡាយណាឱ្យសមស្របទៅតាមនីតិវិធីនៃច្បាប់ ព្រមទាំងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំ នៃព្រះរាជាណាចក្រកម្ពុជា។

៧- ទីភ្នាក់ងារជ្រើសរើសឯកជន និងសមាជិកក្រុមប្រឹក្សាភិបាលរបស់ទីភ្នាក់ងារជ្រើសរើសឯកជន មិនត្រូវធ្លាប់បានប្រព្រឹត្តសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោម ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយៈ

ក- ការគ្រប់គ្រងលុយកាក់ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់កម្មសិក្សាការី និងបេក្ខជន សាច់ញាតិ ឬអ្នកដែលជិតស្និទ្ធជាមួយកម្មសិក្សាការី និងបេក្ខជន ទោះបីជាក្នុងហេតុផលណាមួយក៏ដោយ ដូចជាការប្រមូលប្រាក់ធានា ឬក្នុងគោលបំណងផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស។

ខ- ការចុះកិច្ចសន្យាណាមួយដែលដាក់ការពិន័យជាទឹកប្រាក់ ឬដែលរំពឹងថានឹងមានការផ្ទេរប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀតដោយហួសប្រមាណ ប្រសិនបើកម្មសិក្សាការីមិនបានគោរពទៅតាមកិច្ចសន្យាដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស។

គ- ការរំលោភបំពានសិទ្ធិមនុស្សប្រឆាំងនឹងកម្មសិក្សាការី និងបេក្ខជន ដូចជាការវាយដំ ការបំភិតបំភ័យ និងការបិទសិទ្ធិសេរីភាព។

ឃ- ការប្រើប្រាស់ ឬផ្តល់ឯកសារ រូបភាព ឬគំនូរដែលកែច្នៃ ឬក្លែងបន្លំ ក្នុងគោលបំណងទទួលបានការអនុញ្ញាតដែលក្លែងក្លាយ សម្រាប់នីតិវិធីនៃកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស និងកម្មវិធីអន្តោប្រវេសន៍នៅប្រទេសជប៉ុន។

៨- ត្រូវបញ្ជាក់ថាកម្មសិក្សាការី និងបេក្ខជន សាច់ញាតិ ឬអ្នកដែលជិតស្និទ្ធជាមួយកម្មសិក្សាការី និងបេក្ខជន មិនជាប់ពាក់ព័ន្ធក្នុងសកម្មភាពដែលមានចែងក្នុងចំណុចទី៧ កថាខណ្ឌ(ក) និង(ខ)នោះទេ ដើម្បីរៀបចំឯកសារសម្រាប់ការបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស ក្នុងការបញ្ជូនទៅសមាគមគ្រប់គ្រងនៅប្រទេសជប៉ុន។

៩- ត្រូវសហការជាមួយសមាគមគ្រប់គ្រងរបស់ប្រទេសជប៉ុន និងខិតខំឱ្យអស់ពីលទ្ធភាពក្នុងការទប់ស្កាត់ការបាត់ខ្លួនរបស់កម្មសិក្សាការីជំនាញបច្ចេកទេស។

១០- ត្រូវមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការសម្របសម្រួលរៀបចំឯកសាររបស់បេក្ខជនសម្រាប់កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស ដើម្បីបញ្ជូនបន្តទៅសមាគមគ្រប់គ្រងនៅប្រទេសជប៉ុន។

ក្រុមអធិការការងារទទួលបន្ទុកមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចុះធ្វើអធិការកិច្ចការងារចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ នេះតទៅ ដើម្បីឱ្យស្របតាមបទដ្ឋានអប្បបរមារបស់ភាគីនៃប្រទេសជប៉ុន។

ទទួលបានសារាចរនេះ ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- សមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា
- គ្រប់ទីភ្នាក់ងារជ្រើសរើសឯកជនពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ